# សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល៖

# យោបល់លើសេចក្តីព្រាងច្បាប់លើកទី៣

របាយការណ៍សង្ខេបលីកាដូ

ខែសីហា ឆ្នាំ២០១១

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិ សម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាល តាមរយៈ កម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូអនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរ:**
**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋលើការរំលោភ សិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈ ការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃ អំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន១២កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ទៅកាន់មន្ទីរពេទ្យ។
- **សវាកម្មសង្គមកិច្ច:** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុម

គ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយជាសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណៈជន អំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារបង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង**


លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីម៉ែល: contact@licadho-cambodia.org

គេហទំព័រ: http://www.licadho-cambodia.org/

## ១-ទិដ្ឋភាពទូទៅ

កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ រដ្ឋាភិបាលបានបញ្ចេញសេចក្តីព្រាងច្បាប់លើកទី៣ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាច្បាប់ដែលមានការរិះគន់យ៉ាងខ្លាំង ហើយដែលជាថ្មីម្តងទៀតរដ្ឋាភិបាលលោកបានអះអាងថា សេចក្តីព្រាងថ្មីចុងក្រោយនេះ បានឆ្លើយតបទៅនឹងកង្វល់ជាហូរហែរ ដែលបានលើកឡើងដោយសង្គមស៊ីវិល។ ប៉ុន្តែបើបានក្រឡេកមើលជំពូកទី១វិញ ដែលជាការចាប់ផ្តើមដំបូងនៃច្បាប់នេះ យើងនឹងឃើញថាសេចក្តីព្រាងច្បាប់នេះ ធ្វើអោយមានការប៉ះពាល់ដល់ការធានាអះអាងខាងលើរបស់រាជរដ្ឋាភិបាល។

ការចុះបញ្ជីនៅតែជាកាតព្វកិច្ច ដែលមានន័យថា ប្រជាពលរដ្ឋកម្ពុជាមិនអាចអនុវត្តសិទ្ធិជាមូលដ្ឋានរបស់អ្នកទាំងអស់នោះ ក្នុងការជួបប្រជុំ បញ្ចេញមតិយោបល់ និងការបង្កើតជាសមាគម ដោយមិនបានឆ្លងកាត់និតិវិធីចុះបញ្ជី ប្រកបដោយភាពស្មុគ្រស្មាញ និងទទួលបានការអនុញ្ញាតិពីមន្ត្រីរាជរដ្ឋាភិបាល ដែលជាអ្នកត្រូវបានផ្តល់អោយនូវអំណាចដើម្បីបង្កើត ឬរំលាយក្រុមសង្គមស៊ីវិលនោះទេ។

ភាគច្រើននៃការយល់ឃើញរបស់លីកាដូ ដែលបានផ្តល់នៅក្នុងរបាយការណ៍សង្ខេប ដែលនិយាយអំពីសេចក្តីព្រាងលើកទី១ និងសេចក្តីព្រាងលើកទី២ របស់ច្បាប់នេះនៅតែមានភាពទាក់ទងគ្នា។[១] ដូចគ្នានឹងសេចក្តីព្រាងលើកទី២ដែរ ការកែប្រែដែលបន្សល់នៅក្នុងសេចក្តីព្រាងលើកទី៣ ស្ទើរតែជាការតុបតែងលំអរសំបកខាងក្រៅតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានចំនុចសំខាន់មួយបានធ្វើឲ្យមានការផ្លាស់ប្តូរប្រសើរនៅក្នុងសេចក្តីព្រាងច្បាប់លើកទី៣នោះគឺ បានផ្តល់នូវសិទ្ធិតវ៉ា ចំពោះការបដិសេធលើការចុះបញ្ជី។ ការបន្ថែមចំនុចដែលគួរឲ្យស្វាគមន៍នេះ នៅតែបន្សល់នូវបញ្ហាត្រង់ថា ការដែលមិនមានកំណត់ពេលវេលា និងបទដ្ឋានគតិយុត្តិច្បាស់លាស់សម្រាប់ពិនិត្យលើបណ្តឹងតវ៉ាទាំង

[១] *សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលៈ ការវិភាគចុងក្រោយលើសេចក្តីព្រាងលើកទី២*, របាយការណ៍សង្ខេបលីកាដូ, ខែមីនា ឆ្នាំ២០១១ (មាននៅគេហទំព័រ http://www.licadho-cambodia.org/reports.php?perm =151&pagenb=&filter=-1)។
*សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលៈ សង្គមស៊ីវិលកម្ពុជាស្ថិតក្រោមការគំរាមកំហែង*, របាយការណ៍សង្ខេបលីកាដូ, ខែធ្នូ ឆ្នាំ២០១០ (មាននៅគេហទំព័រ http://www.licadho-cambodia.org/reports.php?perm=150&pagenb=&filter=-1)។

នោះ។ ប៉ុន្តែយ៉ាងតិចណាស់ ក៏ជាការឆ្លុះបញ្ចាំងដ៏សំខាន់មួយ លើលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងក្នុងការងារតស៊ូមតិដែលបាន និងកំពុងធ្វើរហូតដល់ថ្ងៃនេះ។

នៅក្នុងរបាយការណ៍សង្ខេប ដែលវិភាគលើសេចក្តីព្រាងលើកទី១ និងលើកទី២ លីកាដូ បានពន្យល់ក្បោះក្បាយអំពី ថាតើសេចក្តីព្រាងច្បាប់នេះ បានរំលោភសេរីភាពខាងការបញ្ចេញមតិ ខាងការជួបប្រជុំ និងខាងសមាគមរបស់ប្រជាពលរដ្ឋកម្ពុជា ដូចម្តេចខ្លះ ហើយបានសរសេររៀបរាប់អំពីគុណវិបត្តិសំខាន់ៗដូចខាងក្រោម៖

១. ច្បាប់មាននូវការដាក់កំហិត មានល័ក្ខខ័ណ្ឌតម្រូវស្មុគស្មាញ និងផ្តល់នូវដំណើរការសំរាប់ការចុះបញ្ជីស្របច្បាប់ជាអង្គការមិនមែនរដ្ឋាភិបាល និងសមាគមមានលក្ខណៈពិបាក និងបំភិតបំភ័យ។
២. ផ្តល់អំណាចច្រើនដល់មន្ត្រីរដ្ឋាភិបាល និងមិនបានបង្កើតនូវគោលការណ៍ណែនាំដែលអាចបណ្តាលអោយមានការធ្វើសេចក្តីសំរេចតាមទំនើងចិត្ត និងបណ្តាលអោយមានការយកតម្លៃចុះបញ្ជីមិនសមហេតុផល។
៣. ដាក់ល័ក្ខខណ្ឌដោយបង្ខំ ដែលតម្រូវឲ្យអង្គការទាំងអស់ធ្វើរបាយការណ៍ផ្ញើជូនរដ្ឋាភិបាល ដែលជាការរំលោភដល់ឯករាជ្យភាពរបស់អង្គការ។
៤. និងការដាក់កម្រិតមិនសមហេតុផលលើអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលហាក់ដូចជានាំឲ្យមាននយោបាយកម្មយ៉ាងច្រើនដល់ជំនួយមកប្រទេសកម្ពុជា។

ក្រៅតែពីការវិវឌ្ឍវិជ្ជមានមួយចំនួនមាននៅក្នុងសេចក្តីព្រាងច្បាប់ថ្មីនេះ ការវិភាគរបស់លីកាដូកាលពីពេលមុនលើចំណុច ដែលជាកង្វល់ទាំងបួនខាងលើ គឺនៅតែមានដដែលនៅក្នុងសេចក្តីព្រាងច្បាប់នេះ។ ការកែប្រែនៅក្នុងសេចក្តីព្រាងលើកទី៣ មានបញ្ហាពាក់ព័ន្ធនឹងពីរចំណុចខាងលើ ទោះជាយ៉ាងណាក៏ដោយ គឺតម្រូវនូវការវិភាគបន្ថែមទៀតនៅទីនេះ។

## ២-ការកែប្រែសំខាន់ៗនៅក្នុងសេចក្តីព្រាងច្បាប់

ដូចដែលបានពោលខាងលើ ទិដ្ឋភាពច្បាប់ដ៏គួរខ្វល់ខ្វាយបំផុតដែលបន្សល់នៅស្ទើរតែគ្មានការកែប្រែសោះនោះ គឺការតម្រូវអោយមានការចុះបញ្ជីជាកំហិត និងមិនផ្តល់អោយមាននូវការអនុញ្ញាតិជាបណ្តោះអាសន្ន ខណៈពេលរង់ចាំការសម្រេចលើសំណុំបែបបទសុំចុះបញ្ជី។ ទោះបីជាយ៉ាងណាក៏ដោយ បើសំឡឹងមួយភ្លែត បញ្ហានេះអាចនឹងមិនស្តែងចេញអោយឃើញទាំងស្រុងទេ។ មានការបំពេញបន្ថែម នូវភាសាបន្ថែមចាំបាច់មួយចំនួនទៅលើប្រយោគទី១ក្នុងមាត្រា៦ ដែលបើសិនជាអានដោយឡែក អាចនាំអោយអ្នកខ្លះគិតថា ឥឡូវនេះមានការលើកលែងចំពោះការចុះបញ្ជី។ តាមពិត គឺមិនមានការលើកលែងទេ។

គន្លឹះដើម្បីយល់លើការចុះបញ្ជីជាកាតព្វកិច្ចរបស់សេចក្តីព្រាងច្បាប់នេះ គឺស្ថិតលើនិយមន័យដ៏ទូលំទូលាយនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលចែងក្នុងសេចក្តីព្រាងច្បាប់។ មាត្រា៤នៃសេចក្តីព្រាងច្បាប់ បានកំណត់និយមន័យសមាគមសំដៅដល់ក្រុមរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលបានព្រមព្រៀងគ្នាបង្កើតឡើង ដើម្បីគិតគូពីផលប្រយោជន៍សមាជិក ឬ/និងផលប្រយោជន៍សាធារណៈ ដោយមិនធ្វើសកម្មភាពណាមួយទាញយកចំណេញមកចែកគ្នា។ ប្រហាក់ប្រហែលគ្នានេះដែរ សេចក្តីព្រាងច្បាប់បានកំណត់និយមន័យអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដោយសំដៅដល់ក្រុមរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលបានព្រមព្រៀងគ្នាបង្កើតឡើង ដើម្បីធ្វើសកម្មភាពបម្រើផលប្រយោជន៍សាធារណៈ ដោយមិនធ្វើសកម្មភាពណាមួយទាញយកចំណេញមកចែកគ្នា។[២]

យើងត្រូវការត្រឹមតែជំនួសពាក្យ "សមាគម" និង "អង្គការមិនមែនរដ្ឋាភិបាល" ក្នុងមាត្រា៦ ជាមួយនឹងនិយមន័យចេញមកពីក្នុងមាត្រា៤ យើងអាចមើលឃើញថា សេចក្តីព្រាងច្បាប់បច្ចុប្បន្ននៅតែបន្តដាក់កំហិតការចុះបញ្ជីដដែល។

[២] មួយរំពេចយើងអាចមើលឃើញថា និយមន័យពីរនេះមានភាពទូលំទូលាយ ដែលវាអាចត្រួតគ្នា - បើក្រុមប្រជាពលរដ្ឋកម្ពុជាមានបំណងធ្វើការដើម្បីផលប្រយោជន៍សាធារណៈ តើពួកគេជាសមាគម ឬជាអង្គការមិនមែនរដ្ឋាភិបាល?

| មាត្រា៦: បញ្ញត្តិហាមឃាត់ | | |
|---|---|---|
| សេចក្តីព្រាងលើកទី២: មិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះសមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជី ឬចុះអនុស្សរណៈស្របតាមច្បាប់នេះ។ | សេចក្តីព្រាងលើកទី៣: សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជីឬចុះអនុស្សរណៈ នឹងមិនទទួលបានផលប្រយោជន៍ពីច្បាប់នេះទេ ហើយនិងអាចមិនធ្វើសកម្មភាព ជាសមាគម ឬជាអង្គការមិនមែនរដ្ឋាភិបាល[៣] នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[៤] | បញ្ចូលនិយមន័យមកពីមាត្រា៤ ដើម្បីអោយយល់ពីមាត្រា៦: [ក្រុមរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលបានព្រមព្រៀងគ្នា...] ដែលមិនបានចុះបញ្ជី ឬចុះអនុស្សរណៈ នឹងមិនទទួលបានផលប្រយោជន៍ពីច្បាប់នេះទេ ហើយអាចមិនធ្វើសកម្មភាព ជា [ក្រុមរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលបានព្រមព្រៀងគ្នា...] នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ |

ដូច្នេះ ពាក្យបន្ថែមនៅក្នុងឃ្លាទីមួយនៃមាត្រា៦ បង្ហាញអោយឃើញថា គ្មានអ្វីក្រៅតែពីការខិតខំដើម្បីបិទបាំងគោលបំណងសំខាន់របស់ច្បាប់ ដោយបង្កើតអោយមាននូវទំរង់ការនៃការចុះបញ្ជីជាកាតព្វកិច្ច។ តាមពិតសេចក្តីព្រាងច្បាប់លើកទី៣នេះ លុបចោលនូវកិច្ចខិតខំមួយ ដែលមាននៅក្នុងសេចក្តីព្រាងលើកទីពីរ គឺការបើកអោយមានការលើកលែងក្នុងការចុះបញ្ជី ចំពោះ "អង្គការមហាជនដែលបង្កើតឡើងនៅតាមមូលដ្ឋាន មិនស្របតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់នេះ ហើយធ្វើសកម្មភាពស្របតាមច្បាប់នានាជាធរមាន ដើម្បីជួយគ្នាទៅវិញទៅមក។" ការលើកលែងការចុះបញ្ជីនៅក្នុងសេចក្តីព្រាងច្បាប់លើកទី២ តាមពិតសំដៅលើ "អង្គការមហាជន" ជាពាក្យ ដែលត្រូវបានប្រើប្រាស់ក្នុងសម័យកុម្មុយនិស្តទសវត្សរ៍ឆ្នាំ១៩៨០។ ការលើកលែងដែលបង្កប់ដោយភាពអាថិកំបាំងនេះ ក៏មិនឃើញមានទៀតទេក្នុងសេចក្តីព្រាងច្បាប់លើកទី៣។

ទោះជាក្នុងករណីណាក៏ដោយសួរថា ការដែលតំរូវលើការចុះបញ្ជីដែលជាកាតព្វកិច្ចស្ថិតនៅក្រោមច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះ បានទុកឲ្យក្រុមមួយចំនួន

[៣] ឃ្លា "អាចមិនធ្វើសកម្មភាពជាសមាគម..." ក្នុងបញ្ញត្តិនេះមានការពន្យល់ថា: "អាចមិនធ្វើសកម្មភាព*ក្នុងនាមជា* សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។" លីកាដូជឿជាក់ថា "ជាសមាគម" គឺជាការពន្យល់ត្រឹមត្រូវច្រើនជាង។ ទោះបីជាយ៉ាងណា ក៏ការពន្យល់មួយណាក៏ដោយក៏មិនបានអនុញ្ញាតអោយមានការលើកលែងចំពោះការចុះបញ្ជីជាកាតព្វកិច្ចដែរ នៅពេលដែលពិនិត្យព្រមគ្នាជាមួយមាត្រា៤ ដូចដែលបានរៀបរាប់ ខាងលើ។

[៤] មាត្រា៦ បច្ចុប្បន្ន មានបន្ថែមឃ្លាទី២ផងដែរ ដែលលើកលែងចំពោះអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលធ្វើសកម្មភាពតិចជាងមួយឆ្នាំ គិតពីថ្ងៃចុះអនុស្សារណៈ ប៉ុន្តែតម្រូវអោយមានការបញ្ជាក់ជាលាយលក្ខអក្សរអំពីគម្រោងជំនួយរយៈពេល និងទីតាំងធ្វើសកម្មភាពរបស់ពួកគេដាក់ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ លីកាដូ ពិចារណាលើការលើកលែងចំពោះអង្គការមិនមែនរដ្ឋាភិបាលបរទេសនេះ ថាជាការកែប្រែដ៏វិជ្ជមាន។

និងក្រុមនីតិបុគ្គលមិនរកប្រាក់កំរៃមួយចំនួនទៀតធ្វើយ៉ាងដូចម្តេច? នៅខណៈពេលដែលក្រុមទាំងនេះ ក៏មានកំណត់ផងដែរក្នុងក្រមរដ្ឋប្បវេណី ដែលក្រមនេះត្រូវបានដាក់អោយអនុវត្តក្នុងកំឡុងពេល២ឬ៣ខែនាពេលថ្មីៗមកនេះ?[៥] មាត្រា៤៦ ដល់មាត្រា ១១៨ នៃក្រមរដ្ឋប្បវេណី មានបញ្ចូលយ៉ាងលំអិតរួចហើយនូវទម្រង់ការចុះបញ្ជីដោយស្ម័គ្រចិត្ត រួមមានទាំងលក្ខខណ្ឌតម្រូវសម្រាប់ការបង្កើត និងការចុះបញ្ជីទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស និងសមាគម និងមានបញ្ញត្តិគ្រប់គ្រងលើការចុះបញ្ជី ការចាត់ចែង ការរំលាយ និងការជម្រះបញ្ជី។[៦]

ជាការសំខាន់ដើម្បីកត់សំគាល់ផងដែរថា សេចក្តីព្រាងច្បាប់លើកទី៣ ត្រូវបានដាក់ត្រលប់ក្រោយវិញនូវរយៈពេល ៤៥ថ្ងៃ នៃថ្ងៃធ្វើការ គឺយ៉ាងតិចណាស់៩សប្តាហ៍ បើគ្មានថ្ងៃឈប់សំរាកបុណ្យជាតិផ្សេងៗ សម្រាប់រដ្ឋាភិបាលទទួល ឬបដិសេធបែបបទសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ ការកែប្រែនេះមានភាពវិជ្ជមានមែន ប៉ុន្តែនៅតែមានរយៈពេលយូរពេក បើគិតជាមួយនឹងការដែលច្បាប់ចែងពីការហាមឃាត់សកម្មភាពរបស់ក្រុមដែលមិនចុះបញ្ជី។ អាស្រ័យលើថ្ងៃបុណ្យជាតិ រយៈពេលកំណត់នេះអាចត្រូវបានពន្យាលើសពីរយៈពេល៣ខែ ក្នុងអំឡុងពេលដំណាច់ឆ្នាំ។ មិនមានហេតុផលអ្វី ដែលអង្គការមិនមែនរដ្ឋាភិបាល និងសមាគម មិនត្រូវបានអនុញ្ញាតអោយធ្វើសកម្មភាព ខណៈពេលរង់ចាំសេចក្តីសម្រេចលើការចុះបញ្ជីនោះទេ ពីព្រោះថាសម្រាប់ក្រុមហ៊ុនឯកជនទទួលបាននូវការអនុញ្ញាតិបែបនេះ តាមមាត្រា២៦ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងការចុះបញ្ជីឆ្នាំ១៩៩៩ ដែលបានធ្វើវិសោធនកម្ម។

**អំណាចច្រើនរបស់មន្ត្រីរដ្ឋាភិបាលៈ**

ច្បាប់នេះបន្តផ្តល់អំណាចខ្លាំងពេក ដល់ក្រសួងរបស់រដ្ឋាភិបាលក្នុងការងារចុះបញ្ជី។ ការព្រួយបារម្ភបំផុតនោះគឺ លើការខ្វះមូលដ្ឋានច្បាស់លាស់របស់ច្បាប់ សម្រាប់ការបដិសេធការចុះបញ្ជីអោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ ដូច្នេះ នៅតែមិនមានការការពារជាមុន ដើម្បីទប់ស្កាត់ការធ្វើសេចក្តីសំរេចចិត្តតាមទំនើងចិត្តរបស់ក្រសួង។

[៥] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានចុះហត្ថលេខានៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។ ច្បាប់នេះខ្លួនឯង ផ្តល់អោយមានការរង់ចាំរយៈពេល៦ខែ រហូតដល់វាមានអានុភាពអនុវត្ត។

[៦] ក្នុងមាត្រា៤ ក៏មិនមានកិច្ចខិតខំដើម្បីសម្របសម្រួលនិយមន័យដ៏ទូលំទូលាយរបស់វា ជាមួយនឹងសេចក្តីព្រាងច្បាប់ ស្តីពីសហជីព ដែលបច្ចុប្បន្នកំពុងតែស្ថិតក្នុងកិច្ចដំណើការរបស់និតិបញ្ញត្តិ។

ទោះបីជា បែបបទសុំចុះបញ្ជី មិនត្រូវបានបដិសេធទាំងស្រុងក៏ដោយ ក៏លក្ខខ័ណ្ឌតម្រូវជាច្រើនចំពោះការចុះបញ្ជី និងការធ្វើរបាយការណ៍នោះ ផ្តល់ឱកាសដល់មន្ត្រីក្នុងការសំរេចថា សំណុំបែបបទមិនបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ បង្កអោយមានការពន្យាពេល ដែលជាការបំភិតបំភ័យ និងធ្វើអោយមានការរួញរាក្នុងការបន្តដំណើរការសំណុំបែបបទ ឬសកម្មភាព (ជាពិសេស ក្រុមមានមូលដ្ឋាននៅតាមខេត្ត ដែលគ្មានមធ្យោបាយធ្វើដំណើរញឹកញាប់មកកាន់រាជធានីភ្នំពេញ)។[៧]

ទោះបីជាយ៉ាងណាក៏ដោយក៏សេចក្តីព្រាងលើកទី៣ មានបញ្ចូលនូវសិទ្ធិប្តឹងតវ៉ា នៅពេលដែលរដ្ឋាភិបាលបដិសេធការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។[៨] នេះគឺជាសេចក្តីបន្ថែមដ៏គួរឲ្យស្វាគមន៍។ តែជាការគួរសោកស្តាយ បញ្ញត្តិនេះមិនបានផ្តល់នូវគោលការណ៍នៃនាំជាក់លាក់ សម្រាប់ការបដិសេធការចុះបញ្ជី ឬបទដ្ឋានច្បាប់សម្រាប់ការប្តឹងតវ៉ាទេ។ ហើយក៏មិនបានចែង ជាក់លាក់ពីរយៈពេលដែលបណ្តឹងតវ៉ាត្រូវលើកយកមកសវនាការដែរ។ ដោយសារតែច្បាប់ បន្តកំហិតលើការចុះបញ្ជី និងចែងច្បាស់ពីការហាមឃាត់សកម្មភាព ឬប្រតិបត្តិការ មុនមានការយល់ព្រមលើការចុះបញ្ជី ដូច្នេះរយៈពេលកំណត់សវនាការលើបណ្តឹងតវ៉ា គួរតែត្រូវបញ្ជាក់អោយបានច្បាស់លាស់។ មានការចែងយ៉ាងជាក់លាក់លើការកំណត់រយៈពេលទាក់ទងនឹងការអនុញ្ញាត ចំពោះការត្រួតពិនិត្យសំណុំបែបបទសុំចុះបញ្ជីដែលមានរយៈពេលយ៉ាងយូរ និងចំពោះអង្គការដែលត្រូវបានហាម ឃាត់ពីការធ្វើសកម្មភាពខណៈដែលកំពុងរង់ចាំសេចក្តីសំរេចលើសំណុំបែបបទ។

---

[៧] សេចក្តីព្រាងច្បាប់លើកទី៣ ក៏ដូចជាសេចក្តីព្រាងលើកទី២ អនុញ្ញាតអោយក្រសួងមហាផ្ទៃ ធ្វើប្រតិភូកម្មការចុះ បញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ទៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ (*សូមអាន* មាត្រា៧ ក្នុងសេចក្តីព្រាងច្បាប់លើកទី៣ និងមាត្រា២០ ក្នុងសេចក្តីព្រាងច្បាប់លើកទី២។) ក្រោមច្បាប់នេះ ការធ្វើប្រតិភូកម្ម ទោះជាយ៉ាងណានៅតែអាស្រ័យលើការកំណត់របស់ក្រសួងមហាផ្ទៃ។

[៨] *សូមអាន* ពង្រាងលើកទី៣នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មាត្រា១៧។

## ៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សេចក្តីព្រាងច្បាប់លើកទី៣នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅតែជាអត្ថបទច្បាប់ប្រកបដោយគុណវិបត្តិជាខ្លាំង ដែលគោលបំណងច្បាស់លាស់របស់ច្បាប់នេះ គឺដើម្បីតែត្រួតត្រាលើសង្គមស៊ីវិល។ វាមានភាពច្បាស់លាស់តាំងតែពីមានការចេញផ្សព្វផ្សាយ នូវសេចក្តីព្រាងលើកទីមួយមកម្ល៉េះ ដែលច្បាប់នេះមានគោលបំណងបង្កើតឧបសគ្គដល់ការស្ថិតនៅរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈលក្ខខណ្ឌតំរូវនៃការចុះបញ្ជី និងការដាក់របាយការណ៍ ដែលជាការធ្វើអោយអ្នកទាំងនោះចំណាយពេលវេលា និងធនធានដ៏សំខាន់នៅក្នុងដំណើរការដ៏ស្មុគ្រស្មាញ ប្រឈមនឹងការធ្វើសេចក្តីសំរេចចិត្តតាមទំនើងចិត្ត និងមិនត្រឹមត្រូវពីសំណាក់មន្ត្រីរាជរដ្ឋាភិបាល ជាជាងការពង្រឹងដល់សង្គមស៊ីវិល។ សេចក្តីព្រាងច្បាប់លើកទី៣ នៅតែមិនដោះស្រាយចំពោះបញ្ហានេះនៅឡើយ។

ជាថ្មីម្តងទៀត ចូរចងចាំថា សេរីភាពខាងសមាគម បញ្ចេញមតិ និងជួបប្រជុំនៅក្នុងប្រទេសកម្ពុជា មានការដាក់កំហិតយ៉ាងខ្លាំងរួចស្រេចទៅហើយ ជាពិសេសនៅកំរិតសហគមន៍។ ប្រជាពលរដ្ឋធម្មតា ត្រូវបានគេដាក់កំហិត លើលទ្ធភាពបញ្ចេញមតិយោបល់អំពីបញ្ហា ដែលប៉ះពាល់ដល់សុខមាលភាព និងការអភិវឌ្ឍ។ ចំណែកឯ ក្រុមអង្គការមិនមែនរដ្ឋាភិបាល និងក្រុមដទៃទៀតដែលខិតខំប្រឹងប្រែងគាំទ្រ និងធ្វើសកម្មភាពជាមួយអ្នកទាំងនោះ គឺស្ថិតក្នុងបរិយាកាសការងារប្រកបដោយការរឹតត្បិត។ អ្នកណាម្នាក់ ដែលត្រូវបានមើលឃើញថា មានការប្រឈមចំពោះអាជ្ញាធរមូលដ្ឋាន ឬមន្ត្រីរដ្ឋាភិបាល អ្នកនោះអាចនឹងទទួលនូវការធ្វើទុក្ខបុកម្នេញ ដោយរួមមានការចាប់ខ្លួន ការឃុំខ្លួន ការបំភិតបំភ័យ

> ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ។...
>
> *--មាត្រា៤១ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា*
>
> ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។
>
> *--មាត្រា៤២ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា*
>
> ជនគ្រប់រូបមានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។
>
> *--មាត្រា២២ កាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។*

និងអំពើហិង្សា។ ដូច្នេះការពិនិត្យវាយតម្លៃលើសេចក្តីព្រាងច្បាប់នេះ ត្រូវតែធ្វើឡើង ដោយគិតទៅលើបរិបទនេះ។

ដូចកាលពីលើកមុនៗដែរ លីកាដូ សូមផ្តល់អនុសាសន៍ដូចខាងក្រោមៈ

- ការចុះបញ្ជី ត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត។ បញ្ញត្តិច្បាប់ដែលដាក់ការចុះបញ្ជីជាកាតព្វកិច្ច ជាការរំលោភលើរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាផ្ទាល់ ព្រមទាំងបទដ្ឋានអន្តរជាតិ និងសន្ធិសញ្ញាអន្តរជាតិជាច្រើនទៀត ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។ ធ្វើឲ្យច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនស្របទៅនឹងច្បាប់កម្ពុជាមួយចំនួនទៀត ធ្វើអោយមានការយល់ច្រឡំ មិនអាចរកច្រកចេញបានតាមមធ្យោបាយច្បាប់សម្រាប់គ្រប់ក្រុមទាំងអស់ ដែលមានបំណងចង់ចូលរួមប្រជុំ ឬអនុវត្តសកម្មភាពតាមរបៀបទូលំទូលាយមួយ នៅក្នុងប្រទេសកម្ពុជា។
- ច្បាប់គួរតែបញ្ជាក់ថា អង្គការ និងសមាគម ត្រូវបានអនុញ្ញាតជាបណ្តោះអាសន្នអោយធ្វើសកម្មភាព ខណៈដែលកំពុងតែរង់ចាំសេចក្តីសំរេចលើសំណុំបែបបទសុំចុះបញ្ជី។
- រដ្ឋាភិបាលត្រូវតែបញ្ជាក់អោយច្បាស់លាស់អំពីហេតុផលនៃការមានច្បាប់នេះ ជាពិសេស ដោយយោងទៅលើការដែលមានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ របស់កម្ពុជារួចហើយ។ ប្រសិន បើគ្រាន់តែសំអាងលើគោលបំណង ដែលមានចែងកំណត់ក្នុងមាត្រា២ នៃសេចក្តីព្រាងច្បាប់នេះ មិនគ្រប់គ្រាន់ និងមិនអាចទទួលយកបានទាំងស្រុងឡើយ។ ដោយហេតុថា អ្វីដែលបានបញ្ជាក់ក្នុងមាត្រា២នោះ គឺប្រជាពលរដ្ឋកម្ពុជាមានរួចទៅហើយ តាមរយៈរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។[៦] ការចែងពីហេតុផលដ៏សមស្របនឹងជួយអោយអ្នកតាក់តែងច្បាប់របស់កម្ពុជា មានលទ្ធភាពពិនិត្យវាយតម្លៃ លើគោលបំណងរបស់ច្បាប់ដែលមានចែង និងកំណត់ថាតើ មានគុណតម្លៃ ឬសមនឹងទទួលបានការកែប្រែ។

□□□

[៦] *សូមអាន* មាត្រា២ នៃពព្រាងលើកទី៣ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។